# ភ្នំពេញ - អូស្ត្រាលី (១០ថ្ងៃ ៩យប់)

## ថ្ងៃទី១ : ភ្នំពេញ ~ បាងកក ~ ម៉ែលបន



ជួបជុំគ្នានៅព្រលានយន្តហោះអន្តរជាតិភ្នំពេញដើម្បីបន្តដំណើរទៅកាន់ទីក្រុងម៉ែលបនដោយឆ្លងកាត់ទីក្រុងបាងកកវីហុងកុងតាមជើងយន្តហោះ ថៃអ៊ែរ វេស៍ រី ជ្រាហ្គនអ៊ែរ។

## ថ្ងៃទី២ : ម៉ែលបន (អាហារ ៣ ពេល)



ទទួលស្វាគមន៍យ៉ាងរ៉ាក់ទាក់នៅព្រលានយន្តហោះអន្តរជាតិម៉ែលបនដោយមគ្គុទេសក៍ទេសចរណ៍ដ៏ស្ទាត់ជំនាញ។ បន្តដំណើរទៅទស្សនាខ្ទមប្រវត្តិសាស្ត្ររបស់លោក **Captain Cook** ដែលសាងសង់ឡើងនៅប្រទេសអង់គ្លេសនៅឆ្នាំ១៧៥៥និងដឹកមកប្រទេសអូស្ត្រាលីនៅឆ្នាំ១៩៣៤។រួចទស្សនាមជ្ឈមណ្ឌលវិចិត្រសិល្បៈជាតិនិងរាជ្យឧទ្យានរុក្ខសាស្ត្រ។ អាហារថ្ងៃត្រង់រួចជូនទៅទស្សនាចេតិយអនុស្សាវរីយ៍នៃសង្គ្រាមលោកលើកទី១និងទី២ តំបន់កំសាន្តនៅត្រើយខាងកើតនិងកាស៊ីណូគ្រោន ដែលធំជាងគេនៅតំបន់អឌ្ឍគោលខាងត្បូង។ អាហារពេលល្ងាចរួចជូនទៅសណ្ឋាគារសំរាក។

## ថ្ងៃទី៣ : ម៉ែលបន ~ ភ្នំខានដនៀនង ~ តំបន់ស្ព្រីងវែល (អាហារ ៣ ពេល)



អាហារពេលព្រឹករួចជូនទៅភ្នំខានដនៀនងនិងព្រៃ **Sherbrook** បន្តទៅទស្សនាវិចិត្រកម្មនៃយ៉ារ៉ាវលលេ នៅតំបន់ផលិតស្រាមួយក្នុងចំណោមកន្លែងផលិតស្រាដែលធំជាងគេទាំង៤ក្នុងប្រទេសអូស្ត្រាលី។អាហារថ្ងៃត្រង់រួចជូនទៅតំបន់ស្ព្រីងវែល ដែលជាតំបន់ដែលមានបងប្អូនជនជាតិខ្មែររស់នៅច្រើន ហើយ បន្តទៅកោះហ្វីលីព ដើម្បីទស្សនា ការរស់នៅរបស់សត្វឆ្មារសមុទ្រ និងទស្សនាហ្វូងសត្វ **Penguine**។ អាហារពេលល្ងាចសំរាក់នៅសណ្ឋាគារ។

## ថ្ងៃទី៤ : ម៉ែលបន ~ វិថីមហាសមុទ្រ (អាហារ ៣ ពេល)



អាហារពេលព្រឹករួចជូនទៅ ទស្សនាទេសភាពទេសភាពឆ្នេរសមុទ្រ ដែលស្អាតជាងគេនៅក្នុងប្រទេសនៅតាមបណ្តោយ វិថីមហាសមុទ្រនិងទស្សនាទីក្រុងឆ្នេរដ៏មានប្រជាប្រិយ៍ភាព។អាហារថ្ងៃត្រង់រួចជូនទៅទស្សនាឃុំហ្គីឡុងតំបន់ឆ្នេរដែលសំបូរថ្មរកំបោរនិងទស្សនាទេសភាពដ៏អស្ចារ្យនៃសួនឧទ្យានខាំបេលផត។ អាហារពេលល្ងាចរួចជូនទៅ សណ្ឋាគារសំរាក។

## ថ្ងៃទី៥ : ម៉ែលបន ~ កង់បេរ៉ា (អាហារ ៣ ពេល)



អាហារពេលព្រឹករួច បន្តដំណើរទៅ រដ្ឋានីកង់បេរ៉ា រួចបន្តទស្សនា បឹងហ្គ្រីវហ្វីន និងសារៈមន្ទីរសង្គ្រាម។ អាហារថ្ងៃត្រង់រួចជូនទៅទស្សនាវិមានរដ្ឋសភាជាតិនិងឃុំស្ថានទូត។អាហារពេលល្ងាច រួចជូនទៅសណ្ឋាគារសំរាក។

## ថ្ងៃទី៦ : កង់បេរ៉ា ~ ស៊ីតនី (អាហារ ៣ ពេល)



អាហាពេលព្រឹករួចជូនទៅទស្សនាកន្លែងផលិតកាក់និងក្រដាសដុល្លារអូស្ត្រាលីនិងសួនឧទ្យានCockington។អាហារថ្ងៃត្រង់រួចបន្តដំណើរទៅកាន់ទីក្រុងស៊ីតនី។ អាហារពេលល្ងាចរួច ជូនទៅសណ្ឋាគារសំរាក។

## ថ្ងៃទី៧ : ស៊ីតនី (អាហារ ៣ ពេល)



អាហារពេលព្រឹករួចទៅទស្សនាសាលមហោស្រពដ៏ល្បីល្បាញនៅ ប្រទេសអូស្ត្រាលីឈ្មោះថា **Opera House** តំបន់ **The Rock, Mrs. Macquarie's Chair** និង ស្ពាន **Harbour**។ អាហារថ្ងៃត្រង់ដោយកំសាន្តនៅលើប៉ាល់ រួចជូនទៅទស្សនាទីក្រុងរណបKing'sCrossដែលស្ថិតនៅចំងាយ២គីឡូម៉ែតខាងកើតនៃមជ្ឈមណ្ឌលពានិជ្ជកម្មស៊ីតនី។ បន្តទៅទស្សនាព្រះវិហារកាតូលិចសារៈមន្ទីរជាតិ ឆាយណាថោន **Darling Harbour** និង ជូនទៅទិញឥវ៉ាន់ដោយសេរី។ អាហារល្ងាចរួចជូនទៅសណ្ឋាគារសំរាក។

## ថ្ងៃទី៨: ស៊ីតនី (អាហារ ៣ ពេល)



អាហារពេលព្រឹករួចបន្តដំណើរទៅភ្នំខៀវដើម្បីទស្សនាពិភពសត្វព្រៃនិងប្រភេទរុក្ខជាតិ **Flora** និង **Fauna** ដែលមាននៅតែក្នុងប្រទេសនេះប៉ុណ្ណោះ។ បន្តទៅស្រូបយកទេសភាពដ៏ស្រស់ត្រកាលនៅតំបន់ **Jamieson** និង **Megalong Valleys** ទស្សនារូងភ្នំនៀលានដែលសំបូរទៅថ្មកំបោរនៅក្រោមដីដ៏សម្បើម នៅក្នុងប្រទេសអូស្ត្រាលី។ អាហារពេលល្ងាច រួចជូនទៅសណ្ឋាគារសំរាក។

## ថ្ងៃទី៩: ស៊ីតនី ~ បាងកក (អាហារពេលព្រឹក)



អាហារពេលព្រឹករួចជូនទៅទស្សនាឆ្នេរសមុទ្រស៊ីតនីមួយ ចំនួនរួមមានឆ្នេរបាន់ឌី ឈូងសមុទ្រភ្លោះ ឈូងសមុទ្រវ៉ាត់សុន។អាហារថ្ងៃត្រង់រួចជូនទៅ **SouthPoint** និងឧទ្យានអូឡាំពិចដែលជាកន្លែងប្រារព្ធកីឡាអូឡាំពិចនៅក្នុងឆ្នាំ២០០០កន្លងមក។អាហារពេលល្ងាចរួចជូនទៅព្រលានយន្តហោះដើម្បីបន្តដំណើរត្រលប់មកកាន់ទីក្រុងភ្នំពេញដោយឆ្លងកាត់ទីក្រុងបាងកក។

## ថ្ងៃទី១០: បាងកក ~ ភ្នំពេញ (អាហារលើយន្តហោះ)



មកដល់ទីក្រុងបាងកកនៅម៉ោង០៦:០០ព្រឹករួចប្តូរយន្តហោះដើម្បីបន្តដំណើរមកកាន់ទីក្រុងភ្នំពេញវិញប្រកបដោយសុវត្ថិភាព។

**ដំណើរកំសាន្តរួមមាន :**

☞សំបុត្រយន្តហោះទៅមក

☞សណ្ឋាគារផ្កាយ៣ បន្ទប់១ គេង២នាក់

☞អាហារ៣ពេល និង សំបុត្រចូលទស្សនា

☞មគ្គុទ្ទេសប្រាយធ្វើដំណើរនិងមគ្គុទេ

**ដំណើរកំសាន្តមិនរាប់បញ្ចូល :**

☞ទិដ្ឋាការ និង ពន្ធព្រលានយន្តហោះ $88

☞ប្រាក់ទឹកតែសំរាប់មគ្គុទេសក៏ $20

☞ថ្លៃធានារ៉ាប់រងលើសំបុត្រយន្តហោះ $507

☞ថ្ងៃបកប្រែឯកសារ

☞ភេសជ្ជៈ និង រាល់ការចំណាយផ្ទាល់ខ្លួន

**បញ្ជាក់:**

☞ចេញដំណើររាល់ថ្ងៃសុក្រ និងថ្ងៃបុណ្យជាតិផ្សេង និងទៅតាមតំរូវការចំពោះក្រុមដែលមានគ្នា ចាប់ពី១០នាក់ឡើង។

☞ក្មេងក្រោមអាយុ១២ឆ្នាំ ស្នាក់នៅជាមួយឪពុកម្តាយតំលៃ ៧៥% នៃមនុស្សពេញវ័យ

☞សូមរក្សាសិទ្ធិកែប្រែកម្មវិធីក្នុងករណីចាំបាច់

**ព័ត៌មានលំអិតសូមអញ្ជើញទំនាក់ទំនង**


ទូរស័ព្ទលេខ: ០២៣ ២១៨ ៦០៩

អ៊ីមែល: book@asiaexplorertravel.com